**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ០១០២ ព.ណ.អ.ជស

ថ្ងៃ ចន្ទ ៥កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ មករា ឆ្នាំ ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ.អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី១៦ ដល់៣១ ខែមករា ឆ្នាំ២០២១ នឹងត្រូវលក់៣.៥១០រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.១៦០រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី១៦ ដល់៣១ ខែមករា ឆ្នាំ២០២១** នឹងចុះមក៣.៣៥០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.០០០រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) |
|---|---|---|---|
| ១ | Average MOPS | ០,៣៦៧២ដុល្លារ | ០,៣៧៣៤ ដុល្លារ |
| ២ | ពន្ធ៖ | ០,១៨៤៧ ដុល្លារ | ០,០៧៤២ ដុល្លារ |
| | ពន្ធគយ | ០,០៦៣៥ ដុល្លារ | ០,០០០០ ដុល្លារ |
| | អាករបន្ថែម | ០,០២០០ ដុល្លារ | ០,០៤០០ ដុល្លារ |
| | អាករពិសេស | ០,១០១៣ ដុល្លារ | ០,០៣៤២ ដុល្លារ |
| ៣ | PREMIUM | ០,២០ ដុល្លារ | ០,២៣ ដុល្លារ |
| ៤ | អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣) | ០,០៧៥២ ដុល្លារ | ០,០៦៧៨ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៨២៧០ ដុល្លារ | ០,៧៤៥៤ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | ៣.៣៥២ រៀល | ៣.០២១ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៨៣ ដុល្លារ | ០,៧៥ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | ៣.៣៥០ រៀល | ៣.០០០ រៀល |

សម្គាល់៖ អត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ ដែលស្មើនឹង៤០៥៣រៀល/ដុល្លារអាមេរិក

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង<br>EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង<br>DO 0.05% (USD/Barrel) |
|---|---|---|
| ៤ មករា ២០២១ | ៥៦,៥៦ | ៥៨,៣០ |
| ៥ មករា ២០២១ | ៥៤,២០ | ៥៥,៤៧ |
| ៦ មករា ២០២១ | ៥៧,៤៨ | ៥៨,០០ |
| ៧ មករា ២០២១ | ៥៨,២៤ | ៥៨,៣៨ |
| ៨ មករា ២០២១ | ៥៨,៥១ | ៥៩,០៧ |
| ១១ មករា ២០២១ | ៥៩,០៣ | ៥៩,៧១ |
| ១២ មករា ២០២១ | ៥៩,៨៨ | ៦០,៦០ |
| ១៣ មករា ២០២១ | ៦០,៦៥ | ៦១,៤៦ |
| ១៤ មករា ២០២១ | ៦០,១០ | ៦១,៤៧ |
| ១៥ មករា ២០២១ | ៥៩,១៣ | ៦១,២៥ |
| **មធ្យមភាគ១០ថ្ងៃ** | **៥៨,៣៧៨០** | **៥៩,៣៧១០** |
| **មធ្យមភាគ (ដុល្លារ/លីត្រ)** | **០,៣៦៧២** | **០,៣៧៣៤** |

### ក្រាហ្វិកបម្រែបម្រួលថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២០ ដល់ ១៦ ខែមករា ឆ្នាំ២០២១




សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិតាមការណែនាំ ។

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងពាណិជ្ជកម្ម